MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES

SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ អ្នកជំនាញរបស់អង្គការសហប្រជាជាតិ នឹងវាយតម្លៃសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា

ហ្សឺណែវ (៩ មករា ២០២៣)
អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីការការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (IE SOGI) លោក វិកទ័រ ម៉ាឌ្រីហ្គាល់  ប័រឡូស នឹងមកទស្សនៈកិច្ចក្នុងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ១០ ដល់ ថ្ងៃទី២០ ខែកមរា ឆ្នាំ ២០២៣។

«ខ្ញុំមើលឃើញថា ដំណើរទស្សនកិច្ចនេះជាជំហានសំខាន់មួយក្នុងការអនុលោមតាមអាណត្តិ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានផ្តល់ឱ្យខ្ញុំ ដើម្បីធ្វើការសន្ទនា និងស្វែងរកការសហការគ្នា ទាក់ទងនឹងសិទ្ធិមនុស្សនៃសហគមស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងបុគ្គលចម្រុះយេនឌ័រ (អ្នកស្រឡាញ់ភេទដូចគ្នា)។» យោងតាមប្រសាសន៍ របស់លោក ម៉ាឌ្រីហ្គាល់ ប័រឡូស ដែលនឹងមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា តាមការអញ្ជើញរបស់រាជរដ្ឋាភិបាល។ លោកនឹងធ្វើដំណើរទៅទីក្រុងភ្នំពេញ សៀមរាប និងបាត់ដំបង។

អ្នកជំនាញរបស់អង្គការសហប្រជាជាតិនឹងជួបជាមួយអាជ្ញាធររដ្ឋាភិបាល អ្នកការពារសិទ្ធិមនុស្ស និងអ្នកតស៊ូមតិ មេដឹកនាំសាសនា និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ លោកនឹងចូលរួមស្តាប់ទាក់ទងនឹងវិធានការដែលបានអនុម័តឆ្ពោះទៅរកការលុបបំបាត់អំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក៏ដូចជាដើម្បីស្តាប់រាល់ភស្តុតាងទាក់ទងនឹងគម្លាត និងបញ្ហាប្រឈមដែលនៅមានផ្សេងៗទៀត។ លោកក៏នឹងប្រមូលធាតុចូលដើម្បីវិភាគឫសគល់បញ្ហាដែលបណ្តាលឱ្យមានអំពើហិង្សា និងការរើសអើង រួមទាំងផលប៉ះពាល់នៃការរើសអើងក្នុងសង្គម និងភាពប្រសព្វគ្នារាល់ទម្រង់នៃការរើសអើង ។ លោកម៉ាឌ្រីហ្គាល់ ប័រឡូស បាននិយាយថា «ការវាយតម្លៃរបស់ខ្ញុំផ្អែកលើធាតុទាំងអស់នេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ខ្ញុំ ក្នុងការផ្តល់អនុសាសន៍ដល់រដ្ឋជាភាគី និងអ្នកពាក់ព័ន្ធដទៃទៀត។»

អ្នកជំនាញនឹងធ្វើសន្និសីទសារព័ត៌មាននៅថ្ងៃទី២០ ខែមករា វេលាម៉ោង៣រសៀល នៅសណ្ឋាគារ សាន់វ៉េ ភ្នំពេញ ដើម្បីចែករំលែកការរកឃើញបឋមជាមួយប្រព័ន្ធផ្សព្វផ្សាយ។ សន្និសីទសារព័ត៌មាននេះ អនុញ្ញាតឱ្យចូលសម្រាប់តែក្រុមអ្នកសារព័ត៌មានប៉ុណ្ណោះ។

អ្នកជំនាញនឹងបង្ហាញការរកឃើញ និងអនុសាសន៍របស់លោក ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅខែមិថុនា ឆ្នាំ ២០២៣។

ចប់

Office of the High Commissioner for Human Rights www.ohchr.org
Palais des Nations
CH-1211 Geneva 10
Switzerland
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

លោក **វីកទ័រ ម៉ាឌ្រីហ្គាល់ ប័រឡូស** (Victor Madrigal-Borloz) បានទទួលតួនាទីជាអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ លើការការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៨។ លោក **វីកទ័រ ម៉ាឌ្រីហ្គាល់ ប័រឡូស** គឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃកម្មវិធី អេលីន័រ រ៉ូសាវេល (*Eleanor Roosevelt)* កម្មវិធីសិទ្ធិមនុស្សនៃសាកលវិទ្យាល័យច្បាប់ ហារ៉េឌ (Harvard)។ មកដល់ខែមិថុនា ឆ្នាំ២០១៩ លោកបាន បម្រើការជាអគ្គលេខាធិការនៃក្រុមប្រឹក្សាស្តារនីតិសម្បទាអន្តរជាតិសម្រាប់ជនរងគ្រោះដោយសារអំពើទារុណកម្ម (IRCT)។ លោក **ម៉ាឌ្រីហ្គាល់ ប័រឡូស** ជាសមាជិកនៃអនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការបង្ការទារុណកម្មពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៦ ដែលលោក ជាអ្នករាយការណ៍ស្តីពីការការពារការសងសឹក និងមើលការខុសត្រូវលើសេចក្តីព្រាងគោលនយោបាយលើបញ្ហាអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីលើអ្នកស្រលាញ់ភេទដូចគ្នា។ កាលពីមុន លោកបានដឹកនាំការងារបច្ចេកទេសលើសំណុំរឿង របាយការណ៍ និងសក្ខីកម្មជាច្រើន ក្នុងតួនាទីជាប្រធានផ្នែកវិវាទ និងជាប្រធានផ្នែកចុះបញ្ជីនៅគណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ហើយក៏ធ្លាប់បម្រើការនៅនិងវិទ្យាស្ថានសិទ្ធិមនុស្សរបស់ប្រទេសដាណឺម៉ាក (ទីក្រុង កូប៉ិនហាក ប្រទេសដាណឺម៉ាក) និង តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (ទីក្រុងសាន់ចូស ប្រទេសកូស្តារីកា)។

*អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយដែលត្រូវបានគេស្គាល់ថាជា នីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស ជាស្ថាប័នធំជាងគេរបស់អ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សរបស់ អង្គការសហប្រជាជាតិ គឺជាឈ្មោះទូទៅនៃយន្តការស្វែងរកការពិត និងការត្រួតពិនិត្យឯករាជ្យរបស់ក្រុមប្រឹក្សា ដែលដោះស្រាយស្ថានភាពជាក់លាក់របស់ប្រទេសណាមួយ ឬបញ្ហាប្រធានបទនៅគ្រប់ផ្នែកនៃពិភពលោក។ អ្នកជំនាញ នៃនីតិវិធីពិសេសធ្វើការលើមូលដ្ឋានស្ម័គ្រចិត្ត។ ពួកគេមិនមែនជាបុគ្គលិករបស់អង្គការសហប្រជាជាតិ ហើយមិនទទួលបានប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគេទេ។ ពួកគេជាអ្នកឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយធ្វើការតាមសមត្ថភាពរៀងៗខ្លួនរបស់ពួកគេ។*

*តាមដាន IE SOGI ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់គាត់តាមរយៈ Facebook, Instagram, LinkedIn, Twitter*

*សម្រាប់ការស្នើការផ្សព្វផ្សាយស្តីពីអ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាតិ សូមទាក់ទង Manon Beury (+41 22 917 11 85 – manon.beury@un.org)*

*គេហទំព័ររបស់ អង្គការសហប្រជាជាតិទទួលបន្ទុកខាងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា៖ Cambodia*

*សម្រាប់ការស្នើការផ្សព្វផ្សាយស្តីពីអ្នកជំនាញឯករាជ្យផ្សេងទៀតនៃអង្គការសហប្រជាតិ សូមទាក់ទង Maya Derouaz (maya.derouaz@un.org) ឬ Dharisha Indraguptha (dharisha.indraguptha@un.org)*

*តាមដានព័ត៍មានពាក់ព័ន្ធអ្នកជំនាញឯករាជ្យសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅលើ Twitter@UN_SPExperts*